# ការតវ៉ាអោយក្រុមហ៊ុនឡានដឹកដីបាញ់ទឹកលើផ្លូវការពារដីហុយ

## ១. សេចក្តីផ្តើម

ក្រុមស្រ្តីរួមគ្នាដើម្បីអភិវឌ្ឍន៍ គឺជាក្រុមមួយស្ថិតនៅក្នុងភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ក្រុមនេះបានបង្កើតដោយប្រជាជនស្ម័គ្រចិត្តនៅក្នុង ភូមិតានី ក្រោមការសម្របសម្រួលរបស់អង្គការអាដដា-រីដា។ ក្រុមស្ត្រីរួមគ្នាដើម្បីអភិវឌ្ឍន៍មាន សមាជិកសរុបចំនួន ១១នាក់ ក្នុងនោះ មានស្រីចំនួន ៨នាក់ ហើយពួកគេប្រកបរបរធ្វើស្រែចំការ និងលក់ដូរតិចតួច ដើម្បីចិញ្ចឹមជីវិត។

## ២. ស្ថានភាពក្រុមមុនពេលចូលគម្រោង

មុនពេលក្លាយខ្លួនជាអ្នកទទួលផលរបស់គម្រោង ចំរុះបង្កើនសិទ្ធិអំណាចដល់ស្រ្តី, ប្រជាជនដែលរស់នៅក្នុង ភូមិ តានី ឃុំ រុនតាឯក ស្រុក បន្ទាយស្រី បានរស់នៅជាលក្ខណៈដាច់ដោយឡែកពីគ្នា, ពុំសូវមានការសាមគ្គីគ្នា និងប្រកបរបររៀងៗខ្លួនដូចជាធ្វើស្រែ ចិញ្ចឹមសត្វ ជាដើម។ នៅពេលពួកគាត់មានបញ្ហាផ្សេងៗក្នុងភូមិដូចជា ខ្វះខាតផ្លូវ អណ្តូងទឹក បង្គន់អនាម័យ បច្ចេកទេសកសិកម្ម......។ល។ ពួកគាត់មិនហ៊ានស្នើបញ្ហាទាំងនោះទៅអាជ្ញាធរមូលដ្ឋាន(ឃុំ) ដើម្បីជួយដោះស្រាយពួកគាត់ឡើយ។ ទាំងអស់នេះគឺដោយសារតែពួកគាត់មិនមានការសាមគ្គីគ្នានិងមិនយល់ពីច្បាប់ទំលាប់របស់ប្រទេស។

អង្គការអាដដាបានទទួលជំនួយពីប្រទេសដាណឺម៉ាក តាំងពីឆ្នាំ២០០៥ នៅក្នុងខេត្តសៀមរាប និងបានចាប់ដៃគូរសហប្រត្តិបត្តិការណ៍យ៉ាងជិតស្និតជាមួយអង្គការរីដាកម្ពុជា ហើយបានចុះផ្សព្វផ្សាយពីគោលបំណងរបស់គំរោង និងជ្រើសរើសកសិករដែលស្ម័គ្រចិត្តដើម្បីបង្កើតក្រុម នៅថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៧ នៅតាមភូមិគោលដៅមកចូលរួមរៀនវគ្គបណ្តុះបណ្តាលពីសាលារៀនស្រែកសិករចំរុះ។ ដោយឃើញ ពីសារៈប្រយោជន៍ដូចនេះ ពួកគាត់មានចំណាប់អារម្មណ៍យ៉ាងខ្លាំង ហើយក៏បានចុះឈ្មោះចូលរៀនវគ្គសាលាស្រែកសិករចំរុះ។

## ៣. កំឡុងពេលចូលគម្រោង

សាលាស្រែកសិករត្រូវបានបើកវគ្គនៅ ខែ តុលា ឆ្នាំ ២០០៦ នៅក្នុងភូមិតានី ដោយមានអ្នកចូលរួមសរុប ៤៧នាក់, ស្រី៤០នាក់។ វគ្គសាលាស្រែកសិករដែលបានបើកនោះរួមមាន ការដាំបន្លែ និងចិញ្ចឹមសត្វ។ ដោយយល់ពីសារៈសំខាន់នៃការបង្កើតក្រុមជួយខ្លួនឯង កសិករចំនួន ១១នាក់ បានស្ម័គ្រចិត្តរួបរួមគ្នាបង្កើតជាក្រុមមួយឈ្មោះថាក្រុមស្ត្រីរួមគ្នាដើម្បីអភិវឌ្ឍន៍ និងបានចុះបញ្ជីទទួលស្គាល់ជាអង្គការមូលដ្ឋាន (CBO)ពីក្រុមប្រឹក្សាឃុំនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០៧។ ក្នុងពេលដំណើរការក្រុម, អ្នកសម្រប សម្រួលរបស់អង្គការអាដដា និងអង្គការរីដា បានបណ្តុះបណ្តាល បន្ថែមពីស្រ្តីនៃភាពជាអ្នកដឹកនាំ ការតស៊ូមតិ ភារៈកិច្ចរបស់អាជ្ញាធរចំពោះ ប្រជាពលរដ្ឋ និងសារៈសំខាន់នៃការចូលរួមប្រជុំជាមួយ អាជ្ញាធរមូលដ្ឋាន។ល។ សកម្មភាពទាំងនេះធ្វើអោយពួកគាត់យល់កាន់តែ

ច្បាស់ពី តួនាទីរបស់ខ្លួន និងអាជ្ញាធរមូលដ្ឋាន ហើយពួកគាត់ក៏ហ៊ានលើកពីតំរូវការរបស់ខ្លួនដាក់ស្នើជូនអាជ្ញាធរមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ) ដើម្បីជួយដោះស្រាយបញ្ហារបស់ ពួកគេផងដែរ។ ជាក់ស្តែងនៅក្នុងភូមិតានីមាន ផ្លូវលំមួយខ្សែចាក់ដីក្រហម ដែលបានផ្តល់ភាពងាយស្រួលយ៉ាងខ្លាំងដល់ការធ្វើដំណើររបស់អ្នកភូមិ។ នៅខែកុម្ភៈ ឆ្នាំ ២០១២ មានក្រុមហ៊ុនឡានដឹកដីមួយ បានធ្វើចរាចរណ៍លើផ្លូវលំនេះ ហើយបានបង្កភាពលំបាកយ៉ាងខ្លាំង ដល់អ្នកដែលរស់នៅក្នុងភូមិ ពីព្រោះឡានដឹកដីទាំងនោះបានបើកក្នុងល្បឿនយ៉ាងលឿន ដែលធ្វើអោយដីហុយយ៉ាងខ្លាំង ហើយបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពរបស់ អ្នករស់នៅក្នុងភូមិ។ ដោយឃើញស្ថានភាពបែបនេះ សមាជិកក្រុមបានប្រជុំរកវិធីសាស្រ្តដោះស្រាយ។ សមាជិកក្រុមទាំងអស់ក៏បានឯកភាពគ្នាលើកយកបញ្ហានេះ ជូនក្រុមប្រឹក្សាឃុំដើម្បីធ្វើអន្តរាគមន៍ ដោយអោយក្រុមហ៊ុនដឹកដីបាញ់ទឹកលើផ្លូវ ដើម្បីការពារដីហុយ។ ការដាក់សំណើសុំអន្តរា គមន៍ពីក្រុមប្រឹក្សាឃុំ លើក ទី ១ ត្រូវបានទទួលបរាជ័យ ដោយមិនមានមេដៃអ្នកដែលរស់នៅក្នុងភូមិទាំងអស់។ សមាជិកក្រុមក៏បានត្រឡប់មកវិញ ហើយបានប្រជុំគ្នាផ្តិតមេដៃរួចបានដាក់ សំណើនេះទៅក្រុមប្រឹក្សាឃុំម្តងទៀត។ ដោយមានស្នាមមេដៃគ្រប់គ្រាន់ ក្រុមប្រឹក្សាឃុំបានទទួលយកសំណើរនេះ ហើយសន្យាថានឹងដោះស្រាយជូន។ ប៉ុន្តែរយៈពេល៣ខែកន្លងទៅនៅពុំទាន់ឃើញមានការដោះស្រាយណាមួយជូន ពួកគាត់ទេ ពួកគាត់ក៏បានប្រជុំគ្នាម្តងទៀតហើយបានសំរេច លើកល្បិទផ្លូវមិនអោយឡានដឹកដីចូល ដ៏រាបណាក្រុមហ៊ុនឡានដឹកដីនៅតែមិនព្រមបាញ់ទឹកលើផ្លូវ។ ក្រោយការបិទផ្លូវរយៈពេល ៣ថ្ងៃ ក្រុមប្រឹក្សាឃុំ និង តំណាងក្រុមហ៊ុនឡានដឹកដីបានមកពិភាក្សា និងធ្វើកិច្ចសន្យាយល់ព្រមបាញ់ទឹក លើផ្លូវជូនពួកគាត់។ ដោយមានកិច្ចសន្យាត្រឹមត្រូវ ប្រជាពលរដ្ឋរស់នៅក្នុងភូមិបានបើកផ្លូវអោយឡានដឹកដីធ្វើចរាចរណ៍វិញ។ ក្រោយពេលបើកផ្លូវហើយ ក្រុមហ៊ុនឡានដឹកដីបានបាញ់ទឹកលើផ្លូវ ចំនួន ៣ ដងក្នុងមួយថ្ងៃ គឺពេលព្រឹក ថ្ងៃត្រង់ និងពេលល្ងាច។

***<u>សកម្មភាពបិទផ្លូវមិនអោយឡានដឹកដីចូល</u>***





## ៤. សេចក្តីសន្និដ្ឋាន និងចំណាប់អារម្មណ៍

ដោយឃើញលទ្ធផលជាផ្លែផ្កាដូចនេះ សមាជិកក្រុមទាំងអស់កាន់តែមានភាពក្លាហាន និងហ៊ានលើកយកបញ្ហា និងតំរូវការនៅក្នុងភូមិរបស់ពួកគាត់ស្នើអោយអាជ្ញាធរមូលដ្ឋានជួយដោះស្រាយ។ ជាក់ស្តែង, ក្រុមស្ត្រីរួមគ្នាដើម្បីអភិវឌ្ឍន៍បានចាត់អោយតំណាងរបស់ខ្លួនចូលប្រជុំជាមួយក្រុមប្រឹក្សាឃុំដើម្បីបង្ហាញពី លទ្ធផល និងបញ្ហាដែលជួបប្រទះ។ ម្យ៉ាងទៀតពួកគាត់បានទទួលការលើកទឹកចិត្តពីសំណាក់ អាជ្ញា ធរមូលដ្ឋាន (ភូមិ ឃុំ) ក្នុងកិច្ចដំណើរការក្រុមរបស់គាត់ផងដែរ។

*លោកស្រី សន ថា ដែលជាប្រធានក្រុមបានមានប្រសាសន៍ថា “ខ្ញុំមានការសប្បាយចិត្តយ៉ាងខ្លាំងដោយឃើញពីលទ្ធផលនៃការតស៊ូ និងសាមគ្គីគ្នាទាំងក្នុងក្រុម និងភូមិ។ លទ្ធផលទាំងអស់នេះ បានមកពីការសហការណ៍ ការបណ្តុះបណ្តាល និងការជំរុញលើកទឹកចិត្តយ៉ាងខ្លាំងពីសំណាក់ អង្គការអាដដា-វីដា។ ក្រៅពីនេះពួកយើងទាំងអស់គ្នានឹងបន្តលើកយកបញ្ហារបស់ពួកយើងជូនក្រុមប្រឹក្សាឃុំដើម្បីអោយគាត់ជួយធ្វើអន្តរាគមន៍”។*